# យុទ្ធសាស្ត្រចតុកោណ

## ដើម្បីកំណើន ការងារ សមធម៌ និងប្រសិទ្ធភាព

## កសាងមូលដ្ឋានឆ្ពោះទៅសម្រេចចក្ខុវិស័យកម្ពុជា ឆ្នាំ២០៥០

## ដំណាក់កាលទី៤

## របស់រាជរដ្ឋាភិបាល នីតិកាលទី៦នៃរដ្ឋសភា

Domnakseuksa

សេចក្ដីសង្ខេប

# យុទ្ធសាស្ត្រចតុកោណ

## ❋ គោលដៅជាយុទ្ធសាស្ត្រ ទាំង០៤៖

ទី១.ធានាឱ្យបានកំណើនសេដ្ឋកិច្ច ក្នុងអត្រាមធ្យមប្រចាំឆ្នាំក្នុងរង្វង់៧% ប្រកបដោយចីរភាព និងធន់នឹងវិបត្តិ
ទី២.បង្កើតការងារឱ្យបានកាន់តែច្រើន ទាំងបរិមាណ និងគុណភាព ជូនដល់ប្រជាជនកម្ពុជា ពិសេសយុវជន
ទី៣.សម្រេចឱ្យបាននូវគោលដៅនៃការកាត់បន្ថយភាពក្រីក្រ ឱ្យស្ថិតនៅក្នុងអត្រាទាបជាង១០% និងការពារមិនឱ្យភាពក្រីក្រវិលត្រឡប់មកវិញ
ទី៤.បន្តពង្រឹងសមត្ថភាព និងអភិបាលកិច្ចនៃស្ថាប័នរដ្ឋ ទាំងថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ។

## ❋ វិស័យអាទិភាព ទាំង០៤

- ទី១. មនុស្ស
- ទី២. ផ្លូវ
- ទី៣. ទឹក
- ទី៤. ភ្លើង

# យុទ្ធសាស្ត្រចតុកោណ

## រចនាសម្ព័ន្ធយុទ្ធសាស្ត្រចតុកោណ

១.ស្នូលយុទ្ធសាស្ត្រចតុកោណ
“ការបង្កើនល្បឿនកែទម្រង់អភិបាលកិច្ច”

២.បរិស្ថានគ្របដណ្ដប់សម្រាប់
ការអនុវត្តយុទ្ធសាស្ត្រទាំងមូល

៣.ចតុកោណយុទ្ធសាស្ត្រទាំង៤

៤.មុំយុទ្ធសាស្ត្រនៃចតុកោណនីមួយៗ

# ១.ស្ទួលយុទ្ធសាស្ត្រចតុកោណ
## “ការបង្កើនល្បឿនកែទម្រង់អភិបាលកិច្ច”

ការកែទម្រង់ និងលើកកម្ពស់សមត្ថភាពស្ថាប័ន

ការពង្រឹងភាពស្អាតស្អំនៅក្នុងរដ្ឋបាលសាធារណៈ

ការបង្កើនល្បឿនកែទម្រង់អភិបាលកិច្ច

ការពង្រឹងប្រសិទ្ធភាពការអនុវត្តការងារ

ការពង្រឹងអភិបាលកិច្ចវិស័យឯកជន

# ១.ស្នូលយុទ្ធសាស្ត្រចតុកោណ
## "ការបង្កើនល្បឿនកែទម្រង់អភិបាលកិច្ច"

- **គោលដៅជាយុទ្ធសាស្ត្រនៃអភិបាលកិច្ច៖** ការធ្វើទំនើបកម្មស្ថាប័នរដ្ឋ និងការអភិវឌ្ឍប្រកបដោយបរិយាប័ន្ន, សមធម៌ និងយុត្តិធម៌ តាមរយៈការអនុវត្តសិទ្ធិអំណាចរដ្ឋខាងផ្នែកនយោបាយ សេដ្ឋកិច្ច និងរដ្ឋបាល ដោយយកចិត្តទុកដាក់លើអត្ថប្រយោជន៍ប្រជាជនជាស្នូល និងផ្តោតលើការកសាងជាតិ។
- **នីតិកាលកន្លងទៅសម្រេចបាន៖** វឌ្ឍនភាពជាមូលដ្ឋានក្នុងការធ្វើទំនើបកម្មប្រព័ន្ធអភិបាលកិច្ច តាមរយៈការប្រយុទ្ធប្រឆាំងអំពើពុករលួយ, ការកែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌, ការកែទម្រង់រដ្ឋបាលសាធារណៈ, ការកែទម្រង់វិមជ្ឈការនិងវិសហមជ្ឈការ, ការកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ និងការកែទម្រង់កងកម្លាំងប្រដាប់អាវុធ។
- **បញ្ហាប្រឈម៖** ជួបប្រទះបញ្ហាមួយចំនួនពាក់ព័ន្ធនឹងការត្រួតមុខងារនិងដែនសមត្ថកិច្ច, ការជ្រើសរើសនិងការលើកទឹកចិត្តមន្ត្រីរាជការ, ប្រព័ន្ធគណនេយ្យភាព, សមត្ថភាពជំនាញនិងវិជ្ជាជីវៈមន្ត្រីរាជការ, គម្លាតរវាងគោលនយោបាយនិងការអនុវត្ត, ការផ្តល់សេវាយុត្តិធម៌, និងការបង្កើនប្រសិទ្ធភាពនៃការកែទម្រង់កងកម្លាំងប្រដាប់អាវុធ។

Domnakseuksa

# ១.១. ការកែទម្រង់ និងលើកកម្ពស់សមត្ថភាពស្ថាប័ន

➤ **ក្នុងនីតិកាលទី៦ នៃរដ្ឋសភា រាជរដ្ឋាភិបាលនឹងផ្តោតអាទិភាពលើ៖**

ទី១.ការធ្វើវិចារណកម្មមុខងារ និងភារកិច្ច រចនាសម្ព័ន្ធគ្រប់គ្រងស្ថាប័ន និងការសម្របសម្រួលអន្តរស្ថាប័ន

ទី២.ការពង្រឹងភាពជាអ្នកដឹកនាំ, ស្មារតីម្ចាស់ការប្រកបដោយការទទួលខុសត្រូវខ្ពស់ និងសាមគ្គីភាពផ្ទៃក្នុងស្ថាប័ន, ការរៀបចំនិងអនុវត្តហ្មត់ចត់នូវក្រមប្រតិបត្តិសម្រាប់បំពេញការងារ,និងការសម្រិតសម្រាំងរកមន្ត្រីមានសមត្ថភាពខ្ពស់ និងគុណវុឌ្ឍិល្អប្រសើរ សម្រាប់ការតែងតាំងមុខតំណែងដឹកនាំ នៅក្នុងមុខងារសាធារណៈ

ទី៣.ការលើកកម្ពស់គុណាធិបតេយ្យ ក្នុងការជ្រើសរើស/តែងតាំង ការដំឡើងថ្នាក់/ឋានន្តរស័ក្តិ ព្រមទាំងការលើកទឹកចិត្ត និងការផ្តល់អត្ថប្រយោជន៍ផ្សេងទៀតដល់មន្ត្រីសាធារណៈ និងអង្គភាពសាធារណៈ

ទី៤.ការពង្រឹងសមត្ថភាពគ្រប់គ្រងវិស័យសាធារណៈ តាមរយៈការរៀបចំក្របខណ្ឌច្បាប់ និងលិខិតបទដ្ឋាន,ហេដ្ឋារចនាសម្ព័ន្ធការងារ,ក្របខណ្ឌអភិវឌ្ឍមូលធនមនុស្ស និងជំរុញការប្រើប្រាស់បច្ចេកវិទ្យាព័ត៌មាន

ទី៥.ការបន្តកែទម្រង់កងកម្លាំងប្រដាប់អាវុធ។

# ១.២.ការពង្រឹងភាពស្អាតស្អំនៅក្នុងរដ្ឋបាលសាធារណៈ

➢ ក្នុងនីតិកាលទី៦ នៃរដ្ឋសភា រាជរដ្ឋាភិបាលនឹងផ្តោតអាទិភាពលើ៖

ទី១.ការសម្រួចយុទ្ធសាស្ត្រអប់រំ បង្ការ ទប់ស្កាត់ និងបង្ក្រាប ដោយផ្អែកលើផែនការយុទ្ធសាស្ត្រជាតិប្រយុទ្ធប្រឆាំងនឹងអំពើពុករលួយ នៅក្នុងក្របខណ្ឌ "មិនហ៊ាន មិនអាច និងមិនចង់" ប្រព្រឹត្តអំពើពុករលួយ

ទី២.ការពង្រឹង និងពង្រីកការផ្សព្វផ្សាយជាសាធារណៈនូវព័ត៌មានសេវាសាធារណៈ លិខិតបទដ្ឋានគតិយុត្ត និងឯកសារគោលនយោបាយជាតិ

ទី៣.ការជំរុញឱ្យមានការចូលរួមពីសំណាក់ប្រជាជន ក្នុងដំណើរការនៃការអភិវឌ្ឍ ការរៀបចំគោលនយោបាយ និងការអនុវត្ត

ទី៤.ការជំរុញការអនុវត្តយន្តការទទួលព័ត៌មានត្រឡប់ និងដំណោះស្រាយបណ្តឹងតវ៉ារបស់អ្នកប្រើប្រាស់សេវា

ទី៥.ការពង្រឹងប្រសិទ្ធភាពនៃការអនុវត្តយន្តការអធិការកិច្ច និងសវនកម្មក្នុងវិស័យសាធារណៈ

ទី៦.ការពង្រឹងប្រសិទ្ធភាពរៀបចំ និងអនុវត្តក្រមសីលធម៌ការងារ ព្រមទាំងគោលការណ៍វិសមិតភាពមុខងារ និងទំនាស់ផលប្រយោជន៍។

Domnakseuksa

# ១.៣.ការពង្រឹងប្រសិទ្ធភាពអនុវត្តការងារ

- ក្នុងនីតិកាលទី៦ នៃរដ្ឋសភា រាជរដ្ឋាភិបាលនឹងផ្ដោតអាទិភាពលើ៖

  ទី១.បន្តដំឡើងបៀវត្សជូនមន្ត្រីរាជការស៊ីវិល/កងកម្លាំងប្រដាប់អាវុធគ្រប់ប្រភេទ បង្កើនប្រាក់សោធនជូននិវត្តជន និងអតីតយុទ្ធជន ដោយការបើកផ្ដល់តាមធនាគារ ក្នុងរយៈពេល ២សប្ដាហ៍ម្ដង

  ទី២.ការធ្វើប្រតិភូកម្មអំណាច ការផ្ទេរមុខងារ ធនធាន និងការចែករំលែកបច្ចេកទេស តាមរយៈយន្តការវិមជ្ឈការ និងវិសហមជ្ឈការ

  ទី៣.ការជំរុញនវានុវត្តន៍ និងរដ្ឋបាលឯកភាព នៅក្នុងកម្រិតក្រុង-ស្រុក-ខណ្ឌ ខេត្ត-រាជធានី ដើម្បីធានាប្រសិទ្ធភាពក្នុងការបំពេញមុខងារ និងប្រើប្រាស់ធនធាន

  ទី៤.ការដាក់ឱ្យអនុវត្តប្រព័ន្ធគ្រប់គ្រងផ្អែកលើសមិទ្ធកម្ម ដោយប្រើប្រាស់សូចនាករគន្លឹះ( KEY PERFORMANCE INDICATORS )

  ទី៥.ការដាក់ឱ្យប្រើប្រាស់យន្តការតាមដាន និងវាយតម្លៃ

  ទី៦.ការពង្រឹងយន្តការចែករំលែកនិងផ្លាស់ប្ដូរព័ត៌មាន ក្នុងរដ្ឋបាលសាធារណៈនៅគ្រប់កម្រិតទូទាំងប្រទេស

  ទី៧.ការលើកម្ពស់សេវាយុត្តិធម៌ និងពង្រឹងជំនឿទុកចិត្តពីសាធារណៈជនលើវិស័យយុត្តិធម៌។

# ១.៤.ការពង្រឹងអភិបាលកិច្ចវិស័យឯកជន

- ក្នុងនីតិកាលទី៦ នៃរដ្ឋសភា រាជរដ្ឋាភិបាលនឹងផ្ដោតអាទិភាពលើ៖
  ទី១.ការសិក្សា និងការរៀបចំក្របខណ្ឌគោលនយោបាយលើកកម្ពស់អភិបាលកិច្ចក្នុងវិស័យឯកជន
  ទី២.ការសិក្សា និងការរៀបចំក្របខណ្ឌគោលនយោបាយលើកកម្ពស់ការទទួលខុសត្រូវផ្នែកសង្គមនិងបរិស្ថាន
  ទី៣.ការបន្តអនុវត្តយន្តការសន្ទនាក្នុងភាពជាដៃគូរវាងរដ្ឋ និងវិស័យឯកជន ក្នុងកម្រិតគោលនយោបាយ និងបច្ចេកទេស ទាំងនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ។

Domnakseuksa

# ២.បរិស្ថានគ្របដណ្ដប់សម្រាប់ការអនុវត្តយុទ្ធសាស្ត្រទាំងមូល

សន្តិភាព ស្ថេរភាពនយោបាយ និងសណ្ដាប់ធ្នាប់សាធារណៈ

បរិយាកាសអំណោយផល សម្រាប់ធុរកិច្ច ការវិនិយោគ និងការអភិវឌ្ឍ

ពង្រឹងភាពជាម្ចាស់ ភាពជាដៃគូក្នុងការអភិវឌ្ឍ និងសហប្រតិបត្តិការអន្តរជាតិ

ពង្រឹងសមត្ថភាពកម្ពុជា ដើម្បីបន្តជំរុញសមាហរណកម្មខ្លួន ចូលក្នុងសេដ្ឋកិច្ចតំបន់ និងពិភពលោក

# ២.១.សន្តិភាព ស្ថេរភាពនយោបាយ និងសណ្តាប់ធ្នាប់សាធារណៈ

- **នីតិកាលកន្លងទៅសម្រេចបាន៖**ការដោះស្រាយបញ្ហាព្រំដែនជាមួយប្រទេសជិតខាងដោយសន្តិវិធី, ទប់ស្កាត់ដោយជោគជ័យនូវចលនាបដិវត្តន៍ពណ៌, រក្សាស្ថេរភាពនយោបាយ, គោរពសិទ្ធិមនុស្ស, ការបោះឆ្នោតដោយជោគជ័យ, អនុវត្តគោលនយោបាយ "ភូមិ-ឃុំ មានសុវត្ថិភាព" ប្រកបដោយប្រសិទ្ធភាព, បង្ក្រាបនិងទប់ស្កាត់នូវបទល្មើសគ្រប់ប្រភេទយ៉ាងជោគជ័យ។
- **បញ្ហាប្រឈម៖** ការប៉ុនប៉ងរបស់បរទេសក្នុងការជ្រៀតចូលកិច្ចការផ្ទៃក្នុង, ការចិញ្ចឹមចិត្តផ្តួលរំលំរាជរដ្ឋាភិបាលស្របច្បាប់តាមរយៈបដិវត្តន៍ពណ៌,ការប្រើប្រាស់និងជួញដូរគ្រឿងញៀន, បញ្ហាគ្រោះថ្នាក់ចរាចរណ៍, និងអន្តោប្រវេសន៍ខុសច្បាប់ជាដើម។
- **នីតិកាលទី៦ ផ្តោតលើ៖**
  - ទី១.ការពារអធិបតេយ្យជាតិ និងបូរណភាពទឹកដី មិនឱ្យបរទេសណាលូកដៃជ្រៀតជ្រែកកិច្ចការផ្ទៃក្នុង ប្រឆាំងបដិវត្តន៍ពណ៌ ឬការញុះញង់
  - ទី២.ការបន្តពង្រឹងនីតិរដ្ឋ លទ្ធិប្រជាធិបតេយ្យ វប្បធម៌សន្តិភាព សីលធម៌សង្គម ការគោរពសិទ្ធិ និងសេចក្តីថ្លៃថ្នូររបស់មនុស្ស និងពង្រឹងប្រក្រតីភាពក្នុងស្ថាប័នសាធារណៈ
  - ទី៣.បន្តដោះស្រាយបញ្ហាព្រំដែនគោកនិងទឹក និងជំរុញអនុវត្តយុទ្ធសាស្ត្រអភិវឌ្ឍន៍តំបន់ព្រំដែន
  - ទី៤.ទប់ស្កាត់ បង្ក្រាបបទល្មើសគ្រប់ប្រភេទ, ប្រឆាំងភេរវកម្ម ហិរញ្ញប្បទានភេរវកម្ម និងការសម្អាតប្រាក់
  - ទី៥.ពង្រឹងសុវត្ថិភាពចរាចរណ៍ សណ្តាប់ធ្នាប់សាធារណៈ និងការលុបបំបាត់ប៉ុស្តិ៍ត្រួតពិនិត្យមិនស្របច្បាប់
  - ទី៦.ពង្រឹងការអនុវត្តច្បាប់សញ្ជាតិ និង ច្បាប់អន្តោប្រវេសន៍ តាមរយៈការទប់ស្កាត់លំហូរជនអន្តោប្រវេសន៍ខុសច្បាប់
  - ទី៧.ការពង្រឹងការអនុវត្តច្បាប់ និងកសាងសមត្ថភាព ដើម្បីទប់ស្កាត់បទល្មើសតាមប្រព័ន្ធបច្ចេកវិទ្យា។



Domnakseuksa

# ២.២.បរិយាកាសអំណោយផល សម្រាប់ធុរកិច្ច ការវិនិយោគ និងការអភិវឌ្ឍ

- **នីតិកាលកន្លងទៅសម្រេចបាន៖** រក្សាកំណើនជាមធ្យមរង្វង់៧%, ក្លាយជាប្រទេសចំណូលមធ្យមកម្រិតទាបកាលពីឆ្នាំ២០១៦, អត្រាអតិផរណារក្សាក្នុងកម្រិតទាប, អត្រាប្ដូរប្រាក់មានស្ថេរភាព រង្វង់៤០៥០រៀល, និងទុនវិនិយោគ។
- **បញ្ហាប្រឈមក្នុងរយៈពេលមធ្យម៖** ការកើនថ្លៃប្រេង, សង្គ្រាមពាណិជ្ជកម្ម, ការបង្កើនអត្រាការប្រាក់ និងកំណើនយឺតនៃសេដ្ឋកិច្ចប្រទេសអភិវឌ្ឍន៍។

**នីតិកាលទី៦ ផ្ដោតលើ៖**

ទី១.បន្តអនុវត្តគោលនយោបាយម៉ាក្រូសេដ្ឋកិច្ចដោយប្រុងប្រយ័ត្ន

ទី២.ការរៀបចំនូវយន្តការគ្រប់គ្រងវិបត្តិ និងហានិភ័យផ្នែកសេដ្ឋកិច្ចដែលអាចកើតក្នុងវិស័យហិរញ្ញវត្ថុ

ទី៣.ជំរុញបញ្ចប់ការធ្វើវិសោធនកម្មច្បាប់ស្ដីពីវិនិយោគ និងជំរុញអនុវត្តច្បាប់ស្ដីពីតំបន់សេដ្ឋកិច្ចពិសេស

ទី៤.ជំរុញការរៀបចំកែទម្រង់ប្រព័ន្ធពន្ធដារគ្រប់ជ្រុងជ្រោយ និងស៊ីជម្រៅ

ទី៥.រៀបចំ និងជំរុញអនុវត្តនូវយន្តការសម្របសម្រួលដល់ការបង្កើតធុរកិច្ចថ្មី

ទី៦.បន្តកិច្ចសម្រួលពាណិជ្ជកម្ម ដោយរៀបចំបញ្ជរជាតិតែមួយ, កែលម្អយន្តការត្រួតពិនិត្យតាមព្រំដែនក្នុងកម្រិតអប្បបរមា និងកាត់បន្ថយនីតិវិធីមិនចាំបាច់។



Domnakseuksa

# ២.៣.ពង្រឹងភាពជាម្ចាស់ ភាពជាដៃគូក្នុងការអភិវឌ្ឍ និងសហប្រតិបត្តិការ អន្តរជាតិ

- **នីតិកាលកន្លងទៅសម្រេចបាន៖** បានដាក់ឱ្យអនុវត្ត "យុទ្ធសាស្ត្រស្ដីពីកិច្ចសហប្រតិបត្តិការអភិវឌ្ឍ និងភាពជាដៃគូ ឆ្នាំ២០១៤-២០១៨", ពង្រឹងកិច្ចសហប្រតិបត្តិការជាមួយស្ថាប័នអន្តរជាតិនិងប្រទេសជាមិត្តចំនួន១៥៨ ប្រទេស, ក្នុងកម្រិតអាស៊ាន បានបំពេញការងារយ៉ាងសកម្មជាមួយប្រទេសសមាជិកទាំងអស់ដើម្បីសម្រេចគោលដៅអាស៊ានជាសហគមន៍មួយ, កៀរគរហិរញ្ញប្បទានសហប្រតិបត្តិការប្រមាណ ១ប៊ីលានដុល្លា/១ឆ្នាំ, និងបានអនុម័ត"ច្បាប់ស្ដីពីសមាគមនិងអង្គការមិនមែនរដ្ឋាភិបាល"។
- **បញ្ហាប្រឈមក្នុងរយៈពេលមធ្យម៖** ការធ្លាក់ចុះនៃហិរញ្ញប្បទានឥតសំណងដែលត្រូវជំនួសដោយកម្ចីសម្បទាន។

➢ **នីតិកាលទី៦ ផ្ដោតលើ៖**

**ទី១**.បន្តពង្រឹងភាពជាដៃគូប្រកបដោយបរិយាប័ន្នជាមួយបណ្ដាតួអង្គអភិវឌ្ឍន៍

**ទី២**.ការរៀបចំនិងអនុវត្ត "យុទ្ធសាស្ត្រស្ដីពីកិច្ចសហប្រតិបត្តិការអភិវឌ្ឍនិងភាពជាដៃគូឆ្នាំ ២០១៩-២០២៣"

**ទី៣**.ការបន្តចូលរួមយ៉ាងសកម្មក្នុងកិច្ចការតំបន់ និងពិភពលោក ដើម្បីបង្កើនកាលានុវត្តភាពសម្រាប់ការអភិវឌ្ឍ

**ទី៤**.ការបន្តអនុវត្តនូវការប្ដេជ្ញានានាដែលកម្ពុជាបានឯកភាពនៅក្នុងវេទិកាអន្តរជាតិស្ដីពីស័ក្តិសិទ្ធភាពក្នុងកិច្ចអភិវឌ្ឍ

**ទី៥**.បន្តពង្រឹងភាពជាដៃគូជាមួយអង្គការមិនមែនរដ្ឋាភិបាល តាមរយៈការអនុវត្តច្បាប់ស្ដីពីសមាគម និងអង្គការ

**ទី៦**.បន្តពង្រឹងកិច្ចសហប្រតិបត្តិការអន្តរជាតិ និងបង្កើតបន្ថែមនូវយន្តការថ្មីៗដើម្បីទាក់ទាញការវិនិយោគ។

# ២.៤.ពង្រឹងសមត្ថភាពកម្ពុជា ដើម្បីបន្តជំរុញសមាហរណកម្មខ្លួនចូលក្នុងសេដ្ឋកិច្ចតំបន់ និងពិភពលោក

- **នីតិកាលកន្លងទៅសម្រេចបាន៖**ការចូលរួមជាសមាជិកនៃ"សហគមន៍សេដ្ឋកិច្ចអាស៊ាន",បង្កើនការតភ្ជាប់រូបវន្តនិងអរូបវន្តនឹងប្រទេសក្នុងតំបន់, ចូលរួមក្នុងគំនិតផ្ដួចផ្ដើម "ខ្សែក្រវាត់មួយ-ផ្លូវមួយ", និងបានពង្រឹងទំនាក់ទំនងធុរកិច្ចទាំងក្នុងក្របខណ្ឌទ្វេភាគី និងក្របខណ្ឌអាស៊ាន។
- **បញ្ហាប្រឈមក្នុងរយៈពេលមធ្យម៖**ការវិវត្តនៃភូមិសាស្ត្រនយោបាយថ្មីធ្វើឱ្យពាណិជ្ជកម្មពិភពលោកមានភាពមិនច្បាស់លាស់, ការចាកចេញរបស់កម្ពុជាពីឋានៈប្រទេសអភិវឌ្ឍន៍តិចតួច ក៏នឹងបណ្ដាលឱ្យបាត់បង់នូវភាពអនុគ្រោះ។

**នីតិកាលទី៦ ផ្ដោតលើ៖**

**ទី១**.បន្តខិតខំបំពេញនូវកាតព្វកិច្ចសេសសល់នានា ក្នុងក្របខណ្ឌអង្គការពាណិជ្ជកម្មពិភពលោក សហគមន៍អាស៊ាន

**ទី២**.ជំរុញបង្កើតតំបន់ពាណិជ្ជកម្មសេរីទ្វេភាគីជាមួយដៃគូពាណិជ្ជកម្មសំខាន់ៗ និងបង្កើតតំបន់ពាណិជ្ជកម្មសេរីពហុភាគីជាមួយនឹងតំបន់សំខាន់ៗ

**ទី៣**.ការបន្តពង្រឹងការតភ្ជាប់ផ្នែកធុរកិច្ច ដោយរៀបចំឱ្យមានវេទិកាដំណើរទស្សនកិច្ចឬការតាំងបង្ហាញផលិតផល

**ទី៤**.ការបន្តជំរុញការចូលរួមដោយសកម្មរបស់កម្ពុជាក្នុងផ្នែកសមាហរណកម្មសេដ្ឋកិច្ច កម្រិតតំបន់/អន្តរជាតិ

**ទី៥**.ការជំរុញកិច្ចសហប្រតិបត្តិការរវាងក្រសួងស្ថាប័នរបស់រាជរដ្ឋាភិបាល និងគ្រប់តួអង្គអភិវឌ្ឍន៍ផ្សេងទៀត

**ទី៦**.ការបន្តកសាងសមត្ថភាព សម្រាប់ការតាមដាននិន្នាការពាណិជ្ជកម្មនៅគ្រប់វិស័យ។

Domnakseuksa

# ៣.ចតុកោណយុទ្ធសាស្ត្រទាំង៤

ចតុកោណទី១
“ការអភិវឌ្ឍធនធានមនុស្ស”

ចតុកោណទី២
“ការធ្វើពិពិធកម្មសេដ្ឋកិច្ច”

ចតុកោណទី៣
“ការអភិវឌ្ឍវិស័យឯកជន
និងការងារ”

ចតុកោណទី៤
“ការអភិវឌ្ឍប្រកបដោយចីរភាព
និងបរិយាប័ន្ន”

# ចតុកោណទី១
# “ការអភិវឌ្ឍធនធានមនុស្ស”



មុំយុទ្ធសាស្ត្រ

- មុំទី១.ការពង្រឹងគុណភាពវិទ្យាសាស្ត្រ និងបច្ចេកវិទ្យា
- មុំទី២.ការបណ្តុះបណ្តាលជំនាញបច្ចេកទេស
- មុំទី៣.ការលើកកម្ពស់សេវាសុខភាពសាធារណៈ និងអាហារូបត្ថម្ភ
- មុំទី៤.ការពង្រឹងសមភាពយេនឌ័រ និងការគាំពារសង្គម

Domnakseuksa

# មុំទី១.ការពង្រឹងគុណភាពវិទ្យាសាស្ត្រ និងបច្ចេកវិទ្យា

- **នីតិកាលកន្លងទៅសម្រេចបាន៖**អត្រាចូលរៀនខ្ពស់នៅកម្រិតបឋមសិក្សា, ការធ្វើទំនើបកម្មប្រព័ន្ធអប់រំដូចជា៖ បញ្ចូលមុខវិជ្ជាSTEM ក្នុងកម្មវិធីសិក្សា និងសៀវភៅសិក្សាគោល, រៀបចំឱ្យមានសាលារៀនជំនាន់ថ្មី, ការពង្រឹងអធិការកិច្ចអប់រំ, ការកែទម្រង់ឧត្តមសិក្សា, ការរៀបចំនិងអនុវត្តផែនការគោលសម្រាប់ការអប់រំបច្ចេកទេសនៅវិទ្យាល័យចំណេះទូទៅ និងបច្ចេកទេស។
- **បញ្ហាប្រឈម៖**លទ្ធផលសិក្សាមិនទាន់ល្អនៅគ្រប់កម្រិតដូចការរំពឹង,អត្រាបោះបង់ការសិក្សានៅកម្រិតមធ្យមសិក្សានៅតែខ្ពស់,វិសាលភាពនៃការអប់រំបច្ចេកទេសនៅមានកម្រិត និងការចូលរួមពីវិស័យឯកជនក្នុងវិស័យអប់រំនៃបច្ចេកទេសមិនទាន់ទូលំទូលាយ,ការអប់រំមិនទាន់ឆ្លើយតបពេញលេញតាមតម្រូវការទីផ្សារការងារ, គុណភាពឧត្តមសិក្សានៅមានគម្លាតខ្ពស់ធៀបនឹងតម្រូវការ។

**នីតិកាលទី៦ ផ្ដោតលើ៖**

ទី១.បន្តដំឡើងបៀវត្សនិងប្រាក់លើកទឹកចិត្តផ្អែកតាមសមិទ្ធកម្ម,លើកកម្ពស់សមត្ថភាពរបស់នាយកសាលា,លើកកម្ពស់គុណវុឌ្ឍិគ្រូបង្រៀន , ការពង្រាយគ្រូបង្រៀន,អភិវឌ្ឍន៍វិធីសាស្ត្របង្រៀននិងរៀនតាមបែបថ្មី,បន្តការកែទម្រង់ការប្រឡង,វិនិយោគលើសម្ភារសិក្សា, និងជាពិសេសពង្រីកវិសាលភាពសាលារៀនជំនាន់ថ្មី និងការចូលរួមពីសហគមន៍

ទី២.បន្តវិនិយោគលើការកសាងសាលាបឋមសិក្សាឱ្យបានដល់ភូមិនិងអនុវិទ្យាល័យឱ្យបានគ្រប់ឃុំ,បន្តផ្ដល់អាហារូបករណ៍ដល់សិស្សក្រីក្រ និងមានពិការភាព,វិនិយោគដើម្បីអភិវឌ្ឍន៍កុមារតូច,ព្រមទាំងជំរុញការរៀបចំឱ្យមានប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានតាមដានព័ត៌មានសិស្ស

# មុំទី១.ការពង្រឹងគុណភាពវិទ្យាសាស្ត្រ និងបច្ចេកវិទ្យា

ទី៣.ពង្រឹងអធិការកិច្ចលើការគ្រប់គ្រងសាលារៀន,បង្កើនអភិបាលកិច្ចសាលារៀន,រៀបចំឱ្យមានយន្តការចូលរួមជាប្រចាំពីអ្នកពាក់ព័ន្ធ,រៀបចំប្រព័ន្ធពិនិត្យ តាមដាន និងប្រព័ន្ធឆ្លើយ, និងពង្រឹងគុណភាពអប់រំនៅគ្រឹះស្ថានសិក្សាចំណេះទូទៅ

ទី៤.ធ្វើបច្ចុប្បន្នភាពនិងជំរុញអនុវត្តផែនការគោលសម្រាប់ការអប់រំបច្ចេកទេសនៅមធ្យមសិក្សាទុតិយភូមិស្របតាមទស្សនាទាន"ខេត្តមួយមានវិទ្យាល័យចំណេះទូទៅនិងបច្ចេកទេសមួយយ៉ាងតិចសម្រាប់រយៈពេលមធ្យម និងស្រុកមួយមានវិទ្យាល័យចំណេះទូទៅ និងបច្ចេកទេសមួយយ៉ាងតិចសម្រាប់រយៈពេលវែង"

ទី៥.បង្កើនការអប់រំឆ្លើយតបទៅនឹងទីផ្សារការងារនិងការរស់នៅ តាមរយៈទស្សនាទាន "យុវជនម្នាក់មានជំនាញមួយយ៉ាងតិចប្រចាំជីវិត", ពង្រឹងការអប់រំផ្នែក STEM, ជំរុញកម្មវិធីបំណិនជីវិត កម្មវិធីយុវជនក្នុងភាពជាអ្នកដឹកនាំ, និងបន្តបង្កើតក្រុមប្រឹក្សាកុមារនិងយុវជនឱ្យបានគ្រប់សាលារៀន

ទី៦.ការរៀបចំក្របខណ្ឌកម្មវិធីសិក្សាគោលគ្រប់ជ្រុងជ្រោយ,ពង្រឹងយន្តការទទួលស្គាល់គុណភាពឧត្តមសិក្សា,បង្កើនការវិនិយោគលើឧត្តមសិក្សា, បង្កើនមូលនិធិអាហារូបករណ៍និងឥណទានសម្រាប់និស្សិតនៅឧត្តមសិក្សា, ព្រមទាំងបង្កើតក្របខណ្ឌគោលនយោបាយជាតិស្តីពីអភិបាលកិច្ចនិងការគ្រប់គ្រងឧត្តមសិក្សា

ទី៧.ការត្រៀមប្រកួតកីឡាស៊ីហ្គេម(SEA GAME) ឆ្នាំ២០២៣,ជំរុញចលនា "យុវជនម្នាក់ចេះកីឡាមួយប្រភេទយ៉ាងតិចប្រចាំជីវិត" និងរៀបចំវិទ្យាសាស្ត្រសុខាភិបាលកីឡា។

# មុំទី២.ការបណ្ដុះបណ្ដាលជំនាញបច្ចេកទេស

- **នីតិកាលកន្លងទៅសម្រេចបាន៖**បានអនុវត្តគោលនយោបាយជាតិស្ដីពីការអប់រំបណ្ដុះបណ្ដាលបច្ចេកទេសនិងវិជ្ជាជីវៈឆ្នាំ២០១៧-២០២៥,ក្របខណ្ឌគុណវុឌ្ឍិជាតិកម្ពុជា ស្តង់ដារជាតិសមត្ថភាពនិងកម្មវិធីសិក្សាផ្អែកលើសមត្ថភាព,ក្របខណ្ឌទទួលស្គាល់ឆ្លងពីការអប់រំបណ្ដុះបណ្ដាលបច្ចេកទេសនិងវិជ្ជាជីវៈ ទៅគ្រឹះស្ថានឧត្ដមសិក្សា, បង្កើតមជ្ឈមណ្ឌលគំរូសម្រាប់ការបណ្ដុះបណ្ដាលបច្ចេកទេស ជាច្រើនកន្លែង និងបានរៀបចំទិវាជាតិអប់រំបណ្ដុះបណ្ដាលបច្ចេកទេសនិងវិជ្ជាជីវៈ។
- **បញ្ហាប្រឈម៖**ការបណ្ដុះបណ្ដាលជំនាញបច្ចេកទេសកម្រិតមធ្យម/ខ្ពស់នៅមិនទាន់គ្រប់គ្រាន់,ការបង្កើនសមត្ថភាពជំនាញនៃកម្លាំងពលកម្ម ដើម្បីបង្កើនផលិតភាពមិនទាន់ទូលំទូលាយ,គុណភាពនៃការបណ្ដុះបណ្ដាលបច្ចេកទេសមិនទាន់ឆ្លើយតបទៅនឹងតម្រូវការទីផ្សារ,និងការចូលរួមពីវិស័យឯកជននៅមានកម្រិត។
- **នីតិកាលទី៦ ផ្ដោតលើ៖**

  **ទី១.**បន្តជំរុញការអនុវត្ត "គោលនយោបាយជាតិស្ដីពីការអប់រំបណ្ដុះបណ្ដាលបច្ចេកទេសនិងវិជ្ជាជីវៈឆ្នាំ២០១៧-២០២៥

  **ទី២.**បង្កើនកិច្ចសហការរវាងសាលារៀននិងសហគ្រាសក្នុងការបណ្ដុះបណ្ដាលនិងជំរុញការអនុវត្ត"មូលនិធិជាតិសម្រាប់កាអភិវឌ្ឍជំនាញ"

  **ទី៣.**បន្តរៀបចំមជ្ឈមណ្ឌលបណ្ដុះបណ្ដាលជំនាញតាមតម្រូវការជាក់ស្ដែងរបស់វិស័យនីមួយៗ,បង្កើនកិច្ចសហការរវាងរដ្ឋ វិស័យឯកជន អង្គការមិនមែនរដ្ឋាភិបាល គ្រឹះស្ថានបណ្ដុះបណ្ដាល និងសហគ្រាសក្នុងការបណ្ដុះបណ្ដាលជំនាញបច្ចេកទេស

  **ទី៤.**ការធ្វើវិចារណកម្ម និងអភិវឌ្ឍន៍គ្រឹះស្ថានបណ្ដុះបណ្ដាលជំនាញបច្ចេកទេសនិងវិជ្ជាជីវៈ ឆ្លើយតបទៅនឹងតម្រូវការទីផ្សារពលកម្មនិងការចាប់ផ្ដើមធុរកិច្ចថ្មី

  **ទី៥.**ការតម្រង់ទិសវិជ្ជាជីវៈនៅតាមអនុវិទ្យាល័យ និងវិទ្យាល័យក្នុងប្រព័ន្ធអប់រំចំណេះទូទៅ, និងការបង្កើនការផ្សព្វផ្សាយអំពីសារៈសំខាន់ និងភាពចាំបាច់អំពីជំនាញបច្ចេកទេសនិងវិជ្ជាជីវៈ។



Domnakseuksa

- **នីតិកាលកន្លងទៅសម្រេចបាន៖**បានសម្រេចគោលដៅអភិវឌ្ឍន៍សហស្សវត្សក្នុងការកាត់បន្ថយអត្រាមរណៈមាតា ទារក និងកុមារ, កាត់បន្ថយការឈឺនិងស្លាប់ដោយសារជំងឺឆ្លង(អេដស៍ គ្រុនចាញ់ និងរបេង), អាយុសង្ឃឹមរស់កើនដល់ ៧០,៦ឆ្នាំ នៅឆ្នាំ២០១៨, ពង្រីកការគ្របដណ្តប់នៃប្រព័ន្ធគាំពារសង្គម។
- **បញ្ហាប្រឈម៖**សេវាថែទាំសុខភាពបឋមនៅមិនទាន់ឆ្លើយតបបានពេញលេញនិងទាន់ពេលវេលា, គុណភាពនៃការផ្តល់សេវាថែទាំ និងព្យាបាលនៅមានកម្រិត, ចំនួនគ្រូពេទ្យ និងបុគ្គលិកសុខាភិបាលតាមជំនាញនៅពុំទាន់គ្រប់គ្រាន់, ប្រព័ន្ធធានារ៉ាប់រងសុខភាពមិនទាន់គ្របដណ្តប់សម្រាប់ទាំងអស់គ្នា, ការយល់ដឹងពីការប្រើប្រាស់ឱសថ ថ្នាំជក់ គ្រឿងស្រវឹង និងអនាម័យចំណីអាហារនៅមានកម្រិត។
- **នីតិកាលទី៦ ផ្តោតលើ៖**
  - **ទី១.**ជំរុញការអនុវត្ត "ផែនការយុទ្ធសាស្ត្រសុខាភិបាល ២០១៦-២០២០"
  - **ទី២.**ជំរុញវិសាលភាពគ្របដណ្តប់សុខភាពសកលនៅកម្ពុជា, បន្តអនុវត្តរបបសន្តិសុខសង្គមផ្នែកថែទាំសុខភាព
  - **ទី៣.**លើកកម្ពស់គុណភាព សុវត្ថិភាព និងប្រសិទ្ធភាពសេវាសុខភាព(សេវាជាសារវន្ត និងសេវាសង្គ្រោះបន្ទាន់), ដាក់ឱ្យដំណើរការប្រព័ន្ធទទួលស្គាល់គុណភាពនៅមូលដ្ឋានសុខាភិបាល,ពង្រឹងសមត្ថភាពអធិការកិច្ច,រៀបចំនិងពង្រឹងការអនុវត្តច្បាប់ បទបញ្ញត្តិ និងនីតិក្រមសុខាភិបាល,ការផ្លាស់ប្តូរឥរិយាបថរបស់អ្នកផ្តល់សេវាសុខាភិបាល,លើកកម្ពស់សមត្ថភាព និងអភិវឌ្ឍការស្រាវជ្រាវសុខាភិបាល

## មុំទី៣.ការលើកកម្ពស់សេវាសុខភាពសាធារណៈ និងអាហារូបត្ថម្ភ

ទី៤.រៀបចំនិងអនុវត្តឱ្យមានប្រសិទ្ធភាពនូវផែនការយុទ្ធសាស្ត្រអភិវឌ្ឍធនធានមនុស្សក្នុងវិស័យសុខាភិបាល រៀបចំនិងពង្រឹងយន្តការធានានិងទទួលស្គាល់គុណភាពអប់រំវិស័យសុខាភិបាល, អភិវឌ្ឍប្រព័ន្ធទិន្នន័យគ្រប់គ្រងធនធានមនុស្សសុខាភិបាល, គ្រប់គ្រងការពង្រាយបុគ្គលិកសុខាភិបាល និងពង្រឹងយន្តការលើកទឹកចិត្តដ៏សមរម្យជូនដល់បុគ្គលិកសុខាភិបាល

ទី៥.ការពង្រឹងការអនុវត្តច្បាប់ និងបទបញ្ញត្តិពាក់ព័ន្ធនឹងការគ្រប់គ្រងនិងការត្រួតពិនិត្យគុណភាពផលិតផលឱសថ ការប្រើប្រាស់សារធាតុគីមីក្នុងចំណីអាហារ និងការប្រើប្រាស់គ្រឿងស្រវឹង និងថ្នាំជក់

ទី៦.ការជំរុញអនុវត្តវិធានការទប់ស្កាត់ បង្ការ និងកាត់បន្ថយជំងឺ

ទី៧.ការដាក់ឱ្យអនុវត្តកម្មវិធីឧបត្ថម្ភស្ត្រីមានផ្ទៃពោះ និងកុមារអាយុក្រោម០២ឆ្នាំនៃគ្រួសារក្រីក្រ, ការរៀបចំកិច្ចអន្តរាគមន៍ផ្សេងៗសំដៅលើកកម្ពស់អាហារូបត្ថម្ភ និងរៀបចំឱ្យមានយន្តការពហុវិស័យ។

Domnakseuksa

សេចក្តីសង្ខេប

# មុំទី៤.ការពង្រឹងសមភាពយេនឌ័រ និងការគាំពារសង្គម

❖ **នីតិកាលកន្លងទៅសម្រេចបាន៖**បានបញ្ជ្រាបយេនឌ័រទៅក្នុងក្របខណ្ឌគោលនយោបាយ និងផែនការអភិវឌ្ឍជាតិ, បានកាត់បន្ថយគម្លាតយេនឌ័រក្នុងវិស័យអប់រំ,បានពង្រីកសហគ្រិនភាពរបស់ស្ត្រី,កាត់បន្ថយអំពើហិង្សានិងការរំលោភបំពានផ្លូវភេទលើស្ត្រីនិងកុមារ, ពង្រឹងកិច្ចការពារផ្លូវច្បាប់ដល់ស្ត្រីនិងកុមារ,បានដាក់ចេញនិងអនុវត្ត"ក្របខណ្ឌគោលនយោបាយជាតិគាំពារសង្គម២០១៦-២០២៣, កំពុងអនុវត្តគម្រោងស្បៀងបម្រុង កម្មវិធីផ្តល់អាហារតាមសាលារៀន កម្មវិធីអាហាររូបករណ៍ និងកម្មវិធីឧបត្ថម្ភសាច់ប្រាក់ដល់ស្ត្រីមានផ្ទៃពោះ និងកុមារ ព្រមទាំងរបបសន្តិសុខសង្គមទាំងក្នុងវិស័យសាធារណៈនិងវិស័យឯកជន។

❖ **បញ្ហាប្រឈម៖**ការរើសអើងលើស្ត្រីនៅតែមាន,បន្ទុកការងារនិងគ្រួសារនៅតែរារាំងឱកាសស្ត្រីក្នុងការអប់រំ សេដ្ឋកិច្ច សង្គម និងនយោបាយ ,ការជួញដូរនិងអំពើហិង្សាលើស្ត្រីនិងកុមារនៅបន្តកើតមាន,វិសាលភាពគ្របដណ្តប់នៃកម្មវិធីជាតិជំនួយសង្គម និងរបបសន្តិសុខសង្គមនៅមិនទាន់ទូលំទូលាយនិងពេញលេញ។

➢ **នីតិកាលទី៦ ផ្តោតលើ៖**

**ទី១.**ការបន្តលើកកម្ពស់តួនាទីស្ត្រីក្នុងជួរថ្នាក់ដឹកនាំ ទាំងថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិ ទាំងកម្រិតជំនាញនិងនយោបាយ

**ទី២.**ការធ្វើបច្ចុប្បន្នភាព និងអនុវត្ត "ផែនការយុទ្ធសាស្ត្រនារីរតនៈ",បន្តលើកកម្ពស់សហគ្រិនភាពរបស់ស្ត្រី,ទប់ស្កាត់ការជួញដូរ និងអំពើហឹង្សាលើស្ត្រី និងកុមារ



Domnakseuksa

# មុំទី៤.ការពង្រឹងសមភាព យេនឌ័រ និងការគាំពារសង្គម

Domnakseuksa

**ទី៣.** ការជំរុញអនុវត្ត"ក្របខណ្ឌគោលនយោបាយជាតិគាំពារសង្គម២០១៦-២០២៥",គោលនយោបាយជាតិប្រជាជន២០១៦-២០៣០, គោលនយោបាយជាតិស្ដីពីមនុស្សចាស់២០១៧-២០៣០ ព្រមទាំងកែទម្រង់របបសោធន និងការធ្វើសមាហរណកម្មប្រតិបត្តិករប្រព័ន្ធសន្តិសុខសង្គម និងក្របខណ្ឌអភិបាលកិច្ចប្រព័ន្ធគាំពារសង្គម

**ទី៤.** រៀបចំក្របខណ្ឌគតិយុត្ត និងហេដ្ឋារចនាសម្ព័ន្ធគាំទ្រ ដើម្បីដាក់ឱ្យដំណើរការកម្មវិធីជាតិជំនួយសង្គមថ្មីៗ និងពង្រីកកម្មវិធីដែលមានស្រាប់ ព្រមទាំងពង្រីកវិសាលភាពលើរបបដែលមានស្រាប់ សំដៅបង្កើនការគាំពារដល់ប្រជាជនគ្រប់រូប។

# ចតុកោណទី២ “ការធ្វើពិពិធកម្មសេដ្ឋកិច្ច”



**មុំយុទ្ធសាស្ត្រ**

- មុំទី១.ការកែលម្អប្រព័ន្ធឡជីស្ទីក, ការលើកកម្ពស់ការតភ្ជាប់ផ្នែកដឹកជញ្ជូន ថាមពល និងឌីជីថល
- មុំទី២.ការអភិវឌ្ឍប្រភពកំណើនសេដ្ឋកិច្ចគន្លឹះ និងថ្មីៗ
- មុំទី៣.ការរៀបចំខ្លួនសម្រាប់សេដ្ឋកិច្ចឌីជីថល និងឆ្លើយតបនឹងបដិវត្តន៍ឧស្សាហកម្មទី៤
- មុំទី៤.ការជំរុញការអភិវឌ្ឍវិស័យហិរញ្ញវត្ថុនិងធនាគារ

Domnakseuksa

# មុំទី១.ការកែលម្អប្រព័ន្ធឡូជីស្ទីក, ការលើកកម្ពស់ការតភ្ជាប់ផ្នែកដឹកជញ្ជូន ថាមពល និងឌីជីថល

- **នីតិកាលកន្លងទៅសម្រេចបាន៖**គិតត្រឹមដំណាច់ឆ្នាំ២០១៧ បានកសាងទាំងផ្លូវជាតិ និងផ្លូវខេត្តសរុប ១៦ ២៩២គ.ម ដើម្បីទ្រទ្រង់សកម្មភាពសេដ្ឋកិច្ចជាតិ,កម្ពុជាទទួលបានចំណាត់ថ្នាក់មកត្រឹមលេខ៦៨ ក្នុងចំណោម ១៦៧ប្រទេសក្នុងឆ្នាំ២០១៨ ក្នុងសន្ទស្សន៍នៃការវាយតម្លៃឡូជីស្ទីក(LPI)របស់ធនាគារពិភពលោក,កាត់បន្ថយសមាមាត្រនៃការនាំចូលអគ្គិសនីពីប្រទេសជិតខាងពី៦៣,១%មកត្រឹម១៨,៦% នៅឆ្នាំ២០១៧,ផ្នែកឌីជីថល រាជរដ្ឋាភិបាលបានតភ្ជាប់បណ្ដាញខ្សែកាប្លិ៍អុបទិកផ្អឹងខ្នងកើនដល់ប្រវែង ៣៧ ៤៤១គ.ម ព្រមទាំងខ្សែកាប្លិ៍ក្រោមបាតសមុទ្របានចំនួន២ក្នុងឆ្នាំ២០១៧,ការប្រើប្រាស់បច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មានមានកំណើនដោយលេខទូរស័ព្ទចល័តភ្ជាប់សេវាអ៊ិនធឺណិតកើនពី២,៧លានលេខ ក្នុងឆ្នាំ២០១២ ដល់ប្រមាណ១០លាន លេខក្នុងឆ្នាំ២០១៧។
- **បញ្ហាប្រឈម៖**ថ្លៃឡូជីស្ទីកនៅតែខ្ពស់,ការអភិវឌ្ឍនិងការថែទាំហេដ្ឋារចនាសម្ព័ន្ធនៅមានភាពទន់ខ្សោយ និងមិនទាន់គ្រប់គ្រាន់ ព្រមទាំងពុំទាន់ស្របតាមប្លង់គោលរៀបចំដែនដី នគររូបនីយកម្មនិងប្លង់ប្រើប្រាស់ដីធ្លី,ថ្លៃអគ្គិសនីនៅខ្ពស់និងមិនទាន់មានស្ថិរភាព, ផ្នែកឌីជីថលនៅបន្តជួបបញ្ហាពាក់ព័ន្ធការវិនិយោគ និងការប្រើប្រាស់ហេដ្ឋារចនាសម្ព័ន្ធ។

- នីតិកាលទី៦ ផ្តោតលើ៖

ទី១.អនុម័ត និងការអនុវត្តផែនការមេសម្រាប់វិស័យដឹកជញ្ជូនពហុមធ្យោបាយ និងឡជីស្ទីក

ទី២.ការបន្តបង្កើនថវិកាវិនិយោគ និងកៀរគរហិរញ្ញប្បទានដើម្បីស្តារកសាង និងអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធរូបវន្ត ទាំងផ្លូវ គោក ទឹក និងអាកាស ព្រមទាំងផ្លូវល្បឿនលឿន

ទី៣.ការបន្តបញ្ចុះថ្លៃអគ្គិសនី,ពង្រីកបណ្តាញគ្របដណ្តប់និងបង្កើនស្ថិរភាពអគ្គិសនីដោយសាងសង់អនុស្ថានីយ៍បន្ថែម

ទី៤.ការបន្តអភិវឌ្ឍការតភ្ជាប់ផ្នែកឌីជីថល តាមរយៈការពង្រឹងនិងពង្រីកហេដ្ឋារចនាសម្ព័ន្ធខ្សែកាប្លិ៍អុបទិកជាបណ្តាញចែកចាយហេដ្ឋារចនាសម្ព័ន្ធខ្សែកាប្លិ៍អុបទិកឆ្អឹងខ្នង និងខ្សែកាប្លិ៍អុបទិកក្រោមបាតសមុទ្រ ព្រមទាំងហេដ្ឋារចនាសម្ព័ន្ធទូរស័ព្ទ

ទី៥.ការពង្រឹងសមត្ថភាព ក្នុងការធ្វើផែនការ ការរៀបចំថវិកា ការអនុវត្ត និងការត្រួតពិនិត្យវាយតម្លៃគម្រោង។

Domnakseuksa

សេចក្ដីសង្ខេប

# មុំទី២.ការអភិវឌ្ឍប្រកព កំណើនសេដ្ឋកិច្ចគន្លឹះ និងថ្មីៗ

- **នីតិកាលកន្លងទៅសម្រេចបាន៖**សម្រេចបានកំណើនសេដ្ឋកិច្ចខ្ពស់ក្នុងរង្វង់៧% រយៈពេល២ទសវត្សរ៍ចុងក្រោយនេះ។
- **បញ្ហាប្រឈម៖**មូលដ្ឋានទ្រទ្រង់កំណើននៅមិនទាន់ទូលាយ,ចន្ទល់ទ្រទ្រង់កំណើនសេដ្ឋកិច្ចបច្ចុប្បន្ន(ទេសចរណ៍ វាយនភ័ណ្ឌ និងសំណង់) មិនអាចធានាបាននូវកំណើនខ្ពស់ក្នុងរយៈពេលវែង។
- **នីតិកាលទី៦ ផ្ដោតលើ៖**

**ទី១.**ការបន្តជំរុញការអនុវត្ត "គោលនយោបាយអភិវឌ្ឍវិស័យឧស្សាហកម្មកម្ពុជាឆ្នាំ២០១៥-២០២៥" ពិសេសជំរុញការអភិវឌ្ឍខេត្តព្រះសីហនុឱ្យក្លាយទៅជាតំបន់សេដ្ឋកិច្ចពិសេសគំរូពហុបំណង

**ទី២.**រៀបចំ និងអនុវត្តយុទ្ធសាស្រ្តការអភិវឌ្ឍវិស័យកាត់ដេរ និងផលិតស្បែកជើង

**ទី៣.**បន្តជំរុញកិច្ចដំណើរការ និងទាក់ទាញការវិនិយោគនៅតាមតំបន់សេដ្ឋកិច្ចពិសេស

**ទី៤.**រៀបចំផែនការមេអភិវឌ្ឍន៍វិស័យទេសចរណ៍ ដោយផ្ដោតលើការធ្វើពិពិធកម្មផលិតផល និងគោលដៅទេសចរណ៍,ការទាក់ទាញភ្ញៀវចំណាយខ្ពស់ និងការលើកទឹកចិត្តឧស្សាហកម្មគាំទ្រវិស័យទេសចរណ៍

**ទី៥.**ជំរុញការអភិវឌ្ឍវិស័យសេវាផ្នែកកំសាន្ត អក្សរសិល្ប៍ សិល្បៈ គំនូរជីវចល និងភាពយន្ត,ពិសេសផលិតផលបែបប្រពៃណីខ្មែរ

**ទី៦.**ជំរុញការអភិវឌ្ឍវិស័យប្រេងកាតនិងឧស្ម័ន ជាពិសេសការដាក់ដំណើរការអណ្ដូងប្រេងដំបូងឱ្យបានឆាប់ និងពង្រឹងការគ្រប់គ្រងចំណូលដែលបានមកពីធនធានទាំងនេះ។

បដិវត្តន៍ឧស្សាហកម្មសកល បានធ្វើឱ្យមានការផ្លាស់ប្តូរយ៉ាងខ្លាំងនូវស្ថានភាពសង្គម-សេដ្ឋកិច្ចសកល ដូច្នេះរាជរដ្ឋាភិបាលត្រូវរៀបចំខ្លួនចាប់យក កាលានុវត្តភាព និងត្រៀមខ្លួនឆ្លើយតបនឹងបញ្ហាប្រឈម ដែលកើតចេញពីវិស័យសេដ្ឋកិច្ចថ្មីៗ, លើសពីនេះ រាជរដ្ឋាភិបាលត្រូវគ្រប់គ្រងផលវិបាកបណ្តាលមកពីបដិវត្តន៍ឧស្សាហកម្មដូចជា៖ ការប្រែប្រួលនូវរបៀបរបបនៃការធ្វើធុរកិច្ច និងការបាត់បង់ការងារ, អស្ថិរភាពនយោបាយ និងសង្គម, និងការវាយប្រហារ ផ្នែកបច្ចេកវិទ្យាព័ត៌មាន។

- **នីតិកាលទី៦ ផ្តោតលើ៖**

ទី១.រៀបចំនិងអនុវត្តក្របខណ្ឌយុទ្ធសាស្ត្រសេដ្ឋកិច្ចឌីជីថលរយៈពេលវែង និងដាក់វិស័យឌីជីថលជាអនុវិស័យនៅក្នុងប្រព័ន្ធគណនីជាតិ

ទី២.បន្តធ្វើបច្ចុប្បន្នភាព និងអនុវត្តគោលនយោបាយអភិវឌ្ឍន៍វិស័យទូរគមនាគមន៍ និងបច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មាន, ផែនការមេបច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មាន, ច្បាប់ស្តីពីទូរគមនាគមន៍ និងបទប្បញ្ញត្តិពាក់ព័ន្ធនានា

ទី៣.បន្តពង្រឹង និងពង្រីកការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធគាំទ្រចាំបាច់ដូចជា៖ហេដ្ឋារចនាសម្ព័ន្ធបច្ចេកវិទ្យាគមនាគមន៍និងព័ត៌មាន...

ទី៤.ការជំរុញ និងការបង្កើតមូលដ្ឋានគតិយុត្តគាំទ្រដល់ការអភិវឌ្ឍវិស័យឌីជីថល,ជំរុញការអនុវត្តយុទ្ធសាស្ត្ររដ្ឋាភិបាលឌីជីថល និងសន្តិសុខព័ត៌មាន,ច្បាប់ស្តីពីពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក,ច្បាប់ស្តីពីបទល្មើសបច្ចេកវិទ្យាព័ត៌មាន និងវិសោធនកម្មច្បាប់ និងបទប្បញ្ញត្តិពាក់ព័ន្ធ

# មុំទី៣.ការរៀបចំខ្លួនសម្រាប់សេដ្ឋកិច្ចឌីជីថល និងឆ្លើយតបនឹងបដិវត្តន៍ឧស្សាហកម្មទី៤

ទី៩.ការអភិវឌ្ឍជំនាញ និងការអប់រំ ការបណ្ដុះបណ្ដាល ដោយផ្ដោតការប្រើប្រាស់បច្ចេកវិទ្យាឌីជីថលឱ្យបានទូលាយ,បញ្ចូលការប្រើប្រាស់ និងការយល់ដឹងពីបច្ចេកវិទ្យាឌីជីថលទៅក្នុងកម្មវិធីសិក្សា ស្របតាមតម្រូវការទីផ្សារការងារ

ទី៦.ការអភិវឌ្ឍសហគ្រិនភាព និងប្រព័ន្ធអេកូឡូស៊ីឌីជីថល ដែលជាបរិស្ថានអំណោយផលដល់ការបង្កើតធុរកិច្ចថ្មីៗ, ការជំរុញការប្រើប្រាស់ប្រព័ន្ធឌីជីថលក្នុងធុរកិច្ច និងការបង្កើតយន្តការសហប្រតិបត្តិការសហគ្រិនភាព ក្នុងក្របខណ្ឌរាជរដ្ឋាភិបាល ឬភាពជាដៃគូជាមួយវិស័យឯកជន។

# មុំទី៤.ការជំរុញការអភិវឌ្ឍវិស័យហិរញ្ញវត្ថុនិងធនាគារ

- **នីតិកាលកន្លងទៅសម្រេចបាន៖**ការអភិវឌ្ឍគោលនយោបាយនិងក្របខណ្ឌគតិយុត្ត ពិសេសពង្រឹងយន្តការគ្រប់គ្រង និងត្រួតពិនិត្យវិស័យហិរញ្ញវត្ថុ និងធនាគារ,ការពង្រឹងនិងអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធហិរញ្ញវត្ថុ,ការផ្តល់លក្ខខណ្ឌកាន់តែអនុគ្រោះសម្រាប់ប្រជាជនដោយដាក់ពិដានអត្រាការប្រាក់១៨% លើកម្ចីពីគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ,បន្តអភិវឌ្ឍវិស័យធានារ៉ាប់រង និងទីផ្សារមូលបត្រ។
- **បញ្ហាប្រឈម៖**ឧបករណ៍ហិរញ្ញវត្ថុនៅមិនទាន់ត្រូវបានពិពិធកម្មឱ្យអស់លទ្ធភាព,យន្តការបង្ការនិងដោះស្រាយវិបត្តិ ពុំទាន់ត្រូវបានរៀបចំរួចរាល់,ការសម្របសម្រួលគោលនយោបាយនៅមិនទាន់មានភាពល្អប្រសើរគ្រប់គ្រាន់,ចំណេះដឹងផ្នែកហិរញ្ញវត្ថុរបស់ប្រជាជននៅមានកម្រិត,ការសន្សំនៅក្នុងស្រុកនៅមានកម្រិតទាប,អត្រាការប្រាក់នៅមានកម្រិតខ្ពស់នៅឡើយ,កម្រិតខ្ពស់នៃដុល្លារូបនីយកម្ម ដែលដាក់កំហិតលើប្រសិទ្ធភាពគោលនយោបាយរូបិយវត្ថុ និងការអភិវឌ្ឍវិស័យធានារ៉ាប់រងនៅមានកម្រិត។

## នីតិកាលទី៦ ផ្តោតលើ៖

**ទី១.**បន្តអនុវត្ត "យុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុឆ្នាំ២០១៦-២០២៥",ការបន្តអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធប្រកចេញ-ចូលនៃប្រព័ន្ធទូទាត់, ការជំរុញការអភិវឌ្ឍប្រព័ន្ធទូទាត់ដោយប្រើបច្ចេកវិទ្យាហិរញ្ញវត្ថុ,សម្របសម្រួលគោលនយោបាយនិងក្របខណ្ឌគតិយុត្តពង្រឹងសមត្ថភាពស្ថាប័ននិងធនធានមនុស្សក្នុងវិស័យហិរញ្ញវត្ថុនិងធនាគារ

**ទី២.**បន្តធានាស្ថិរភាពហិរញ្ញវត្ថុ,ការពន្លឿនដំណើរការបង្កើតគណៈកម្មាធិការស្ថិរភាពហិរញ្ញវត្ថុ,អភិវឌ្ឍយន្តការបង្ការនិងដោះស្រាយវិបត្តិ

# មុំទី៤.ការជំរុញការអភិវឌ្ឍ វិស័យហិរញ្ញវត្ថុនិងធនាគារ

ទី៣.បន្តពង្រីកតួនាទីវិស័យធនាគារ,សិក្សា និងរៀបចំគោលនយោបាយ និងយន្តការដើម្បីពង្រីកវិសាលភាពសេវាហិរញ្ញវត្ថុ,ពង្រីកគោលការណ៍គាំពារអ្នកប្រើប្រាស់សេវាហិរញ្ញវត្ថុ

ទី៤.បន្តអភិវឌ្ឍន៍ទីផ្សារមូលបត្រ,លើកកម្ពស់យន្តការជួញដូរ, និង បង្កើតប្រតិបត្តិការទីផ្សារមូលបត្រអនាគត

ទី៥.សិក្សា និងរៀបចំឱ្យមានទីផ្សារសញ្ញាបណ្ណរដ្ឋសម្រាប់ជាមូលដ្ឋានកំណត់អត្រាការប្រាក់គោល,កៀរគរធនធានហិរញ្ញវត្ថុសម្រាប់វិនិយោគសាធារណៈ និងពង្រឹងគោនយោបាយរូបិយវត្ថុ

ទី៦.ជំរុញការអភិវឌ្ឍនិងប្រើប្រាស់បច្ចេកវិទ្យាហិរញ្ញវត្ថុ( FIN TECH )ក្នុងវិស័យធនាគារនិងហិរញ្ញវត្ថុ

ទី៧.លើកកម្ពស់និងបង្កើនសមត្ថភាពវិភាគ តាមដាន និងត្រួតពិនិត្យកិច្ចការប្រឆាំងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម

ទី៨.បន្តលើកកម្ពស់ការប្រើប្រាស់ប្រាក់រៀល,លើកកម្ពស់ការយល់ដឹងរបស់ប្រជាជនលើវិស័យហិរញ្ញវត្ថុ

ទី៩.បន្តពង្រឹងនិងពង្រីកផលិតផលធានារ៉ាប់រងថ្មីៗ, ពង្រឹងសមត្ថភាពបញ្ញត្តិធានារ៉ាប់រង និងកិច្ចការពារអ្នកប្រើប្រាស់។

# ចតុកោណទី៣
# "ការអភិវឌ្ឍវិស័យឯកជននិងការងារ"

Domnakseuksa

**មុំយុទ្ធសាស្ត្រ**

- មុំទី១.ការអភិវឌ្ឍទីផ្សារការងារ
- មុំទី២.ការលើកស្ទួយសហគ្រាសធុនតូចនិងមធ្យម និងសហគ្រិនភាព
- មុំទី៣.ការរៀបចំនិងអនុវត្តភាពជាដៃគូរវាងវិស័យសាធារណៈ និងវិស័យឯកជន
- មុំទី៤.ការពង្រឹងការប្រកួតប្រជែង

# មុំទី១.ការអភិវឌ្ឍទីផ្សារការងារ

- **នីតិកាលកន្លងទៅសម្រេចបាន៖**ចំនួនរោងចក្រសហគ្រាស និងគ្រឹះស្ថានគ្រប់ប្រភេទ បានកើនដល់ ៥៨ម៉ឺនសហគ្រាស ដោយផ្តល់ការងារជាង ៤លាននាក់នៅឆ្នាំ២០១៧,ពលករទេសន្តរប្រវេសន៍កើនដល់ ១,១៥លាននាក់នៅឆ្នាំ២០១៧ និងនាំប្រាក់ចំណូលមកក្នុងប្រទេសជាង១,៧ប៊ីលានដុល្លាអាម៉េរិកជាមធ្យមក្នុង១ឆ្នាំ,ប្រាក់ឈ្នួលអប្បបរមាក្នុងវិស័យវាយនភណ្ឌកាត់ដេរ និងផលិតស្បែកជើង,កើនដល់១៧០ដុល្លាអាម៉េរិកក្នុង១ខែ នៅឆ្នាំ២០១៨,សិទ្ធិសេរីភាព លក្ខខណ្ឌការងារ និងភាពសុខដុមរមនាត្រូវបានលើកកម្ពស់។
- **បញ្ហាប្រឈម៖**គុណភាព និងផលិតភាពនៃកម្លាំងពលកម្មនៅមានកម្រិតទាប បើធៀបនឹងប្រទេសក្នុងតំបន់,ប្រព័ន្ធគ្រប់គ្រងទិន្នន័យការងារ និងអតីតភាពការងារមិនទាន់រឹងមាំ,ប្រព័ន្ធគ្រប់គ្រងសុខភាពនិងសុវត្ថិភាពការងារមិនទាន់ល្អ,សេវាគាំពារពលករទេសន្តរប្រវេសន៍នៅមានកម្រិត និងការគ្រប់គ្រងការបិទរោងចក្រ និងការទូទាត់ប្រាក់អតីតភាពការងារនៅមិនទាន់ល្អ។
- **នីតិកាលទី៦ ផ្តោតលើ៖**

  ទី១.បន្តពង្រឹងយន្តការ "វេទិកាការងារ",ផ្តល់ការបណ្តុះបណ្តាលតម្រង់ទិសមុនចូលធ្វើការ និងពង្រីកការផ្តល់សេវារកការងារ

  ទី២.អនុវត្តច្បាប់ស្តីពីប្រាក់ឈ្នួលអប្បបរមាឱ្យមានប្រសិទ្ធភាព,រៀបចំបើកប្រាក់ឈ្នួលប្រចាំខែក្នុងរយៈពេល២សប្តាហ៍ម្តង និងទូទាត់ប្រាក់អតីតភាពការងារប្រចាំឆ្នាំឱ្យបានទៀងទាត់ដល់កម្មករ-និយោជិត

  ទី៣.ពង្រឹងនិងពង្រីកការអនុវត្តកម្មវិធីហ្វឹកហ្វឺនកូនជាង/កម្មសិក្សា

  ទី៤.ពង្រឹងគុណភាពនិងប្រសិទ្ធភាពអធិការកិច្ចការងារ និងពង្រឹងប្រព័ន្ធទិន្នន័យកម្មករនិយោជិត

# មុំទី១.ការអភិវឌ្ឍទីផ្សារការងារ

ទី៥.ពង្រឹងភាពសុខដុមរមនានៅក្នុងទំនាក់ទំនងវិជ្ជាជីវៈ

ទី៦.បន្តពង្រឹងអភិបាលកិច្ចទេសន្តរប្រវេសន៍ការងារ និងពង្រីកកិច្ចសហប្រតិបត្តិការពហុភាគី និងទ្វេភាគី,ទប់ស្កាត់ទេសន្តរប្រវេសន៍ការងារដោយខុសច្បាប់,លើកកម្ពស់ការគាំពារសិទ្ធិ ផលប្រយោជន៍ សុខភាព និងសុវត្ថិភាពការងារ កិត្តិយស និងសេចក្តីថ្លៃថ្នូរបស់ពលករ, និងរៀបចំធ្វើសមាហរណកម្មពលករទេសន្តរប្រវេសន៍ដែលធ្វើមាតុភូមិនិវត្ត

ទី៧.បន្តពង្រឹងការតបណ្តាញអគ្គិសនី និងទឹកស្អាតតម្លៃទាបសមរម្យជូនកម្មករ-និយោជិត សិស្ស-និស្សិត នៅតាមផ្ទះជួល,ជំរុញការរៀបចំកន្លែងស្នាក់នៅ និងមធ្យោបាយធ្វើដំណើរ សម្រាប់កម្មករ-និយោជិតដោយសុវត្ថិភាព,ការអនុញ្ញាតឈប់លំហែមាតុភាពរយៈពេល៣ខែដោយទទួលប្រាក់ឈ្នួលពលកម្ម១២០% និងការឧបត្ថម្ភផ្សេងៗ,ការផ្តល់សេវាថែទាំសុខភាព និងការពិនិត្យផ្ទៃពោះដល់កម្មការីដោយឥតគិតថ្លៃ នៅតាមមន្ទីរពេទ្យ/មណ្ឌលសុខភាពរដ្ឋ, និងការបន្តកែសម្រួលកម្រិតប្រាក់ឈ្នួលអប្បបរមា។

# មុំទី២.ការលើកស្ទួយសហគ្រាសធុនតូចនិងមធ្យម និងសហគ្រិនភាព

- **នីតិកាលកន្លងទៅសម្រេចបាន៖**បានពង្រឹងបរិស្ថានធុរកិច្ចសម្រាប់ការអភិវឌ្ឍសហគ្រាសធុនតូច និងមធ្យម តាមរយៈការពង្រឹងអភិបាលកិច្ច ការផ្ដល់ការលើកទឹកចិត្តផ្នែកសារពើពន្ធ ការលើកកម្ពស់ស្តង់ដារគុណភាពផលិតផល និងការធានាបាននូវស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច ,សហគ្រាសធុនតូចនិងមធ្យម កម្មន្តសាលនិងសិប្បកម្ម ដែលបានចុះបញ្ជីនៅក្រសួងឧស្សាហកម្ម និងសិប្បកម្ម មានចំនួនជិត ១៦ម៉ឺន កន្លែង និងប្រើប្រាស់កម្លាំងពលកម្មសរុបចំនួនជាង១លាននាក់ គិតត្រឹមឆ្នាំ២០១៧។
- **បញ្ហាប្រឈម៖**ការផ្ដល់សេវាសាធារណៈ និងការសម្របសម្រួលស្ថាប័ន នៅមិនទាន់មានប្រសិទ្ធភាពល្អ ស្មុគស្មាញ និងចំណាយពេលច្រើន, ការទទួលបានឥណទាននៅមានកម្រិត និងប្រកពទុនវិនិយោគនៅមានភាពចង្អៀត,ការលើកទឹកចិត្តផ្នែកពន្ធមិនទាន់មានលក្ខណៈគ្រប់ជ្រុងជ្រោយ , កង្វះខាតនូវសហគ្រិនភាព និងហេដ្ឋារចនាសម្ព័ន្ធគាំទ្រ។

➢ **នីតិកាលទី៦ ផ្ដោតលើ៖**

**ទី១.**បញ្ចប់ការរៀបចំ និងការជំរុញការអនុវត្ត "គោលនយោបាយគាំទ្រសហគ្រាសធុនតូច និងមធ្យម" ឱ្យមានប្រសិទ្ធភាព

**ទី២.**ពង្រឹងយន្តការគាំទ្រ,ការផ្ដល់សេវាសម្របសម្រួល,ការផ្សព្វផ្សាយនិងបញ្ជ្រាបបច្ចេកវិទ្យាថ្មី និងការខិតខំស្វែងរកទីផ្សារនាំចេញ

**ទី៣.**ការបង្កើត"ធនាគារសហគ្រាសធុនតូចនិងមធ្យម"

**ទី៤.**ការបង្កើត "មូលនិធិជាតិសហគ្រិនភាព" និង "មជ្ឈមណ្ឌលអភិវឌ្ឍសហគ្រិនភាព" ដោយសហការជាមួយវិស័យឯកជន

**ទី៥.**ពង្រឹង និងពង្រីកបន្ថែមការវិនិយោគលើហេដ្ឋារចនាសម្ព័ន្ធគាំទ្រ

**ទី៦.**ការជំរុញការលើកកម្ពស់គុណភាពផលិតផលនៃសហគ្រាសធុនតូច និងមធ្យម ព្រមទាំងលើកកម្ពស់នវានុវត្តន៍។

# មុំទី៣.ការរៀបចំនិងអនុវត្តភាពជាដៃគូរវាងវិស័យសាធារណៈ និងវិស័យឯកជន

- **នីតិកាលកន្លងទៅសម្រេចបាន៖**បានដាក់ចេញនូវ "ឯកសារគោលនយោបាយស្ដីពីការអភិវឌ្ឍយន្តការភាពជាដៃគូរវាងរដ្ឋ និងឯកជន សម្រាប់គ្រប់គ្រងគម្រោងវិនិយោគសាធារណៈ២០១៦-២០២០",បានបង្កើតយន្តការស្ថាប័ន និងបានអនុវត្តគម្រោងវិនិយោគធំៗ ក្នុងវិស័យហេដ្ឋារចនាសម្ព័ន្ធដឹកជញ្ជូន ថាមពល និងបច្ចេកវិទ្យាគមនាគមន៍និងព័ត៌មាន ជាពិសេសក្នុងទម្រង់"សាងសង់-អាជីវកម្ម-ផ្ទេរ"។
- **បញ្ហាប្រឈម៖**ការប្រើប្រាស់"យន្តការចំពោះកិច្ច"ក្នុងការអនុវត្តគម្រោងភាពជាដៃគូរវាងរដ្ឋនិងឯកជន មិនទាន់មានការវាយតម្លៃហានិភ័យនៃគម្រោងហិរញ្ញវត្ថុ,ក្របខណ្ឌគតិយុត្តមិនទាន់គ្រប់គ្រាន់,សមត្ថភាពផ្ដួចផ្ដើមរៀបចំការចរចារ និងការគ្រប់គ្រងគម្រោងនៅមានកម្រិត។

➢ **នីតិកាលទី៦ ផ្ដោតលើ៖**

**ទី១.**បន្តអនុវត្ត "ឯកសារគោលនយោបាយស្ដីពីការអភិវឌ្ឍយន្តការភាពជាដៃគូរវាងរដ្ឋ និងឯកជន សម្រាប់គ្រប់គ្រងគម្រោងវិនិយោគសាធារណៈ២០១៦-២០២០" និងរៀបចំ "គោលនយោបាយអនុវត្តគម្រោងវិនិយោគសាធារណៈក្រោមយន្តការភាពជាដៃគូរវាងរដ្ឋនិងឯកជន" សម្រាប់រយៈពេលវែង

**ទី២.**បន្តរៀបចំក្របខណ្ឌគតិយុត្ត និងបទប្បញ្ញត្តិពាក់ព័ន្ធ និងការដាក់ឱ្យអនុវត្តនីតិវិធីគ្រប់គ្រងប្រតិបត្តិការរួម

**ទី៣.**បន្តអភិវឌ្ឍន៍សមត្ថភាពស្ថាប័ន និងធនធានមនុស្សតាមក្រសួងស្ថាប័ន លើការគ្រប់គ្រង និងអនុវត្តគម្រោង

**ទី៤.**បន្តអភិវឌ្ឍគម្រោងវិនិយោគសាធារណៈ តាមរយៈយន្តការភាពជាដៃគូរវាងរដ្ឋនិងឯកជន

Domnakseuksa

# មុំទី៤.ការពង្រឹងការប្រកួតប្រជែង

❖ **នីតិកាលកន្លងទៅសម្រេចបាន៖**សន្ទស្សន៍នៃភាពប្រកួតប្រជែងសកលរបស់កម្ពុជាត្រូវបានកែលម្អឱ្យប្រសើរឡើងពីចំណាត់ថ្នាក់ទី១១២ ក្នុងចំណោម១១៧ប្រទេស នៅឆ្នាំ២០០៥ មកចំណាត់ថ្នាក់ទី៩៤ ក្នុងចំណោម ១៣៧ ប្រទេស នៅឆ្នាំ២០១៧-២០១៨។

❖ **បញ្ហាប្រឈម៖**កង្វះក្របខណ្ឌច្បាប់ក្នុងការលើកកម្ពស់ការប្រកួតប្រជែងដោយស្មើភាព និងស្មោះត្រង់,សមត្ថភាពកែច្នៃ និងបង្កើតតម្លៃបន្ថែមនៅមានកម្រិត,កង្វះពលកម្មជំនាញ,និងប្រសិទ្ធភាពនៃវិស័យគាំទ្រនៅមានកម្រិត។

➢ **នីតិកាលទី៦ ផ្តោតលើ៖**

**ទី១.**ការជំរុញរៀបចំ និងអនុម័តច្បាប់ស្តីពីការប្រកួតប្រជែង(ANTI-TRUST/COMPETITION LAW),ពង្រឹងរចនាសម្ព័ន្ធឧស្សាហកម្ម, រៀបចំយន្តការសម្រាប់អនុវត្តច្បាប់ និងលើកកម្ពស់វប្បធម៌ប្រកួតប្រជែង

**ទី២.**ការពិនិត្យឡើងវិញ និងធ្វើវិសោធនកម្មច្បាប់ស្តីពីក្ស័យធន

**ទី៣.**ជំរុញការអនុវត្តយន្តការមជ្ឈត្តការផ្នែកពាណិជ្ជកម្ម(COMMERCIAL ARBITRATION)

**ទី៤.**បន្តជំរុញការរៀបចំ និងការអនុវត្តស្តង់ដាទំនិញ សេវា និងការគ្រប់គ្រង

**ទី៥.**ជំរុញការរៀបចំ និងអនុម័តច្បាប់ស្តីពីការការពារអ្នកប្រើប្រាស់(CONSUMER PROTECTION LAW) និងរៀបចំយន្តការអនុវត្ត ដើម្បីការពារសិទ្ធិ និងសុវត្ថិភាពអ្នកប្រើប្រាស់

**ទី៦.**ពង្រឹងយន្តការជំរុញការប្រកួតប្រជែងដោយស្មើភាព និងការអនុវត្តលទ្ធកម្មសាធារណៈប្រកបដោយតម្លាភាព និងភាពត្រឹមត្រូវ។

Domnakseuksa

# ចតុកោណទី៤
# "ការអភិវឌ្ឍប្រកបដោយចីរភាព និងបរិយាប័ន្ន"

មុំទី១.ការលើកស្ទួយវិស័យកសិកម្ម និងការអភិវឌ្ឍជនបទ

មុំទី២.ការគ្រប់គ្រងធនធានធម្មជាតិ និងវប្បធម៌ប្រកបដោយចីរភាព

មុំយុទ្ធសាស្ត្រ

មុំទី៣.ការពង្រឹងការគ្រប់គ្រងនគរូបនីយកម្ម

មុំទី៤.ការធានាចីរភាពបរិស្ថាន និងការរៀបចំខ្លួនឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុ



Domnakseuksa

# មុំទី១.ការលើកស្ទួយវិស័យកសិកម្ម និងការអភិវឌ្ឍជនបទ

- **នីតិកាលកន្លងទៅសម្រេចបាន៖**វិស័យកសិកម្មបានផ្ដល់ការងាររហូតដល់ ៤១,៥% ,កម្ពុជាបានផលិត និងនាំចេញនូវកសិផលច្រើនមុខ ពិសេសបាននាំចេញអង្ករជាង ៦០ម៉ឺនតោន ក្នុងឆ្នាំ២០១៧, និងមានការពង្រីកហេដ្ឋារចនាសម្ព័ន្ធនៅតាមតំបន់ជនបទ។
- **បញ្ហាប្រឈម៖**ផលិតភាពនៅមានកម្រិត,គុណភាពទាបនៃធាតុចូលកសិកម្ម,ការផ្ដល់សេវាបច្ចេកទេសមិនទាន់ឆ្លើយតបនឹងតម្រូវការ,ការចិញ្ចឹមសត្វ និងវារីវប្បកម្មនៅមានកម្រិត,យន្តការនាំចូលកសិផល ប្រព័ន្ធអនាម័យ មិនទាន់រឹងមាំ,ខ្វះយន្តការព័ត៌មានទីផ្សារ, និងការប្រើប្រាស់ជីធ្លីកសិកម្មនៅមិនទាន់អស់សក្ដានុពល។

➢ **នីតិកាលទី៦ ផ្ដោតលើ៖**

**ទី១.**ការជំរុញរៀបចំ និងដាក់ឱ្យអនុវត្ត "ផែនការមេសម្រាប់អភិវឌ្ឍវិស័យកសិកម្មឆ្ពោះទៅឆ្នាំ២០៣០" និង "ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យកសិកម្មឆ្នាំ២០១៩-២០២៣"

**ទី២.**ការបន្តជំរុញការរៀបចំ អនុម័ត និងអនុវត្ត"ច្បាប់ស្ដីពីការការពាររុក្ខជាតិ និងភូតគាមអនាម័យ"និង"ច្បាប់ស្ដីពីផលិតកម្មកសិកម្មតាមកិច្ចសន្យា"

**ទី៣.**ការបង្កើនផលិតភាព គុណភាព និងពិពិធកម្ម តាមរយៈការវិនិយោគលើការស្រាវជ្រាវ និងអភិវឌ្ឍន៍ពូជដំណាំ ពូជសត្វ និងការចិញ្ចឹមត្រីដែលផ្ដល់តម្លៃបន្ថែមខ្ពស់,ជំរុញការអភិវឌ្ឍកសិដ្ឋានគំរូ( MODEL FARM ), និងពង្រឹងការគ្រប់គ្រងសហគមន៍កសិករ,បន្តការបន្ថយថ្លៃ និងពង្រឹងគុណភាពនៃធាតុចូលកសិកម្ម, និងការជំរុញការប្រើប្រាស់បច្ចេកវិទ្យាវៃឆ្លាត និងឱជីជីថល

**ទី៤.**លើកកម្ពស់ឧស្សាហកម្មកែច្នៃ ដោយជំរុញឱ្យមានការវិនិយោគឯកជន និងរៀបចំយុទ្ធសាស្ត្រតាមមុខដំណាំនីមួយៗ

Domnakseuksa

សេចក្តីសង្ខេប

# មុំទី១.ការលើកស្ទួយវិស័យ កសិកម្ម និងការអភិវឌ្ឍជនបទ

ទី៥.បន្តជំរុញដាំបន្លែគ្រប់ប្រភេទជំនួសឱ្យការនាំចូល និងការរៀបចំបង្កើតទីផ្សារបោះដុំ និងចែកចាយបន្លែ ដែលមានស្តង់ដារ

ទី៦.ជំរុញពាណិជ្ជូបនីយកម្មកសិកម្ម ដោយបន្តពង្រឹងប្រព័ន្ធអនាម័យនិងភូតគាមអនាម័យ(SPS),ការសម្រួលពាណិជ្ជកម្ម,វិនិយោគបន្ថែមលើមន្ទីរពិសោធន៍គុណភាពសម្រាប់ការនាំចេញ, និងជំរុញការផលិត និងការប្រើប្រាស់ផលិតផលក្នុងស្រុក

ទី៧.ជំរុញការចិញ្ចឹមសត្វ និងវារីវប្បកម្ម តាមរយៈការបន្តអនុវត្ត "ច្បាប់ស្តីពីសុខភាពសត្វ និងផលិតកម្មសត្វ", "ក្របខណ្ឌផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យបសុសត្វឆ្នាំ២០១៦-២០២៥"និង"ផែនការយុទ្ធសាស្ត្រជាតិអភិវឌ្ឍន៍វារីវប្បកម្មឆ្នាំ២០១៦-២០២៥"

ទី៨.ពង្រឹងការគ្រប់គ្រងដីសម្បទានសេដ្ឋកិច្ច,ការបន្តជំរុញការបោសសម្អាតមីន យុទ្ធភណ្ឌមិនទាន់ផ្ទុះ និងបន្តផ្តល់ដីសម្បទានសង្គមកិច្ច

ទី៩.ការធ្វើវិចារណកម្មក្នុងការវិនិយោគលើប្រព័ន្ធធារាសាស្ត្រ

ទី១០.ការបន្តជំរុញការអភិវឌ្ឍជនបទឱ្យរស់រវើក។

Domnakseuksa

សេចក្ដីសខ្មែរ

# មុំទី២.ការគ្រប់គ្រងធនធានធម្មជាតិ និងវប្បធម៌ប្រកបដោយចីរភាព

- **នីតិកាលកន្លងទៅសម្រេចបាន៖**គម្របព្រៃឈើត្រូវបានរក្សាក្នុងរង្វង់ ៦០%នៃផ្ទៃប្រទេស,ដីសម្បទានសេដ្ឋកិច្ចជាង ៤១ម៉ឺនហិចតាត្រូវបានដកហូត,កន្លែងអភិរក្សជលផលជាង៩៧ម៉ឺនហិចតា ត្រូវបានអភិរក្ស,សហគមន៍ព្រៃឈើ ចំនួន៦១០ និងសហគមន៍នេសាទចំនួន៥១៦ ត្រូវបានបង្កើត,បេតិកភណ្ឌវប្បធម៌រូបីនិងអរូបីជាច្រើនត្រូវបានដាក់បញ្ចូលក្នុងបញ្ជីបេតិកភណ្ឌនៃអង្គការយូណេស្កូ។
- **បញ្ហាប្រឈម៖**អភិបាលកិច្ច និងប្រព័ន្ធគ្រប់គ្រងធនធានរ៉ែ នៅមិនទាន់រឹងមាំ និងការធ្វើអាជីវកម្មរ៉ែនៅមានអនាធិបតេយ្យ,ការឈូសឆាយដីព្រៃធ្វើកម្មសិទ្ធិ,ការទន្ទ្រានដីព្រៃលិចទឹក និងដែននេសាទ,បទល្មើសព្រៃឈើ សត្វព្រៃ និងជលផលនៅបន្តកើតមាន។

**នីតិកាលទី៦ ផ្ដោតលើ៖**

- ទី១.ការជំរុញអនុវត្ត "គោលនយោបាយជាតិស្ដីពីធនធានរ៉ែ ឆ្នាំ២០១៨-២០២៨" ដើម្បីពង្រឹងអភិបាលកិច្ចគ្រប់គ្រងធនធានរ៉ែ
- ទី២.ពង្រឹងយន្តការគ្រប់គ្រងធនធាន និងអាជីវកម្មខ្សាច់
- ទី៣.បន្តគ្រប់គ្រងធនធានព្រៃឈើ និងសត្វព្រៃ ដោយរក្សាគម្របព្រៃឈើឱ្យលើស៦០%នៃផ្ទៃប្រទេស,ទប់ស្កាត់ការទន្ទ្រានកាន់កាប់ និងឈូសឆាយដីព្រៃធ្វើកម្មសិទ្ធិ,លើកកម្ពស់ការចូលរួមរបស់សហគមន៍ និងបង្ក្រាបបទល្មើសព្រៃឈើ
- ទី៤.បន្តជំរុញការអភិរក្ស និងគ្រប់គ្រងធនធានជលផល
- ទី៥.លើកកម្ពស់ការថែរក្សាប្រព័ន្ធអេកូឡូស៊ី និងការការពារតំបន់ធម្មជាតិ
- ទី៦.បន្តអភិរក្ស និងអភិវឌ្ឍន៍បេតិកភណ្ឌវប្បធម៌


Domnakseuksa

# មុំទី៣.ការពង្រឹងការគ្រប់គ្រងនគរូបនីយកម្ម

- **នីតិកាលកន្លងទៅសម្រេចបាន៖**អនុម័ត និងដាក់ឱ្យអនុវត្តនូវគោលនយោបាយជាតិស្ដីពីការរៀបចំដែនដី,បានរៀបចំចក្ខុវិស័យនៃយុទ្ធសាស្ត្រតម្រង់ទិសអភិវឌ្ឍរាជធានីភ្នំពេញ,បានដាក់ឱ្យអនុវត្តប្លង់គោលប្រើប្រាស់ដីរាជធានីភ្នំពេញឆ្នាំ២០៣៥,បានអភិវឌ្ឍប្លង់នគរូបនីយកម្ម និងកំពុងកសាងទីរួមខេត្តត្បូងឃ្មុំ,បានអនុម័តប្លង់គោលប្រើប្រាស់ដីនៅខេត្តព្រះសីហនុនិងខេត្តបាត់ដំបង,បានអនុម័តគោលនយោបាយជាតិស្ដីពីលំនៅឋាន និងគោលនយោបាយស្ដីពីការលើកទឹកចិត្ត និងការបង្កើតកម្មវិធីជាតិសម្រាប់ការអភិវឌ្ឍលំនៅឋានតម្លៃសមរម្យ,បានសាងសង់លំនៅឋានតម្លៃសមរម្យមួយចំនួនក្នុងរាជធានីភ្នំពេញ និងខេត្តកណ្ដាល,បានរៀបចំប្រព័ន្ធព័ត៌មានវិទ្យាគ្រប់គ្រងទិន្នន័យសំណង់, និងបានផ្ដល់ប័ណ្ណកម្មសិទ្ធិដីធ្លី ដីសម្បទានសង្គមកិច្ច និងសាងសង់ផ្ទះជូនគ្រួសារយោធិន និងនគរបាលគ្រួសារអតីតយុទ្ធជន ពលី ពិការ មរណៈ និងបាត់បង់សមត្ថភាពការងារ ដែលមានជីវភាពក្រីក្រ។
- **បញ្ហាប្រឈម៖**ប្លង់គោលប្រើប្រាស់ដី និងយុទ្ធសាស្ត្រតម្រង់ទិសអភិវឌ្ឍន៍នៅមិនទាន់ត្រូវបានសិក្សាចប់ និងអនុម័តសម្រាប់ខេត្តក្រុងភាគច្រើន,ការតាំងទីលំនៅមិនទាន់មានសណ្ដាប់ធ្នាប់ល្អនៅឡើយ,ការរំលោភយកចំណីផ្លូវ,ការរំលោភបំពានលើបឹងធម្មជាតិដីគម្របព្រៃ និងការចាប់យកដីសាធារណៈនៅមិនទាន់ត្រូវបានដោះស្រាយបានល្អ,ផែនការមេអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធរូបវន្តទីក្រុង មិនទាន់ត្រូវបានរៀបចំឱ្យមានភាពប្រទាក់ក្រឡា,ការដឹកជញ្ជូន និងចរាចរណ៍នៅក្នុងក្រុងមិនទាន់មានសណ្ដាប់ធ្នាប់ល្អ និងមិនទាន់រៀបចំបាននូវក្របខណ្ឌច្បាស់លាស់ សម្រាប់លើកកម្ពស់សោភ័ណភាព និងអភិរក្សសំណង់ប្រវត្តិសាស្ត្រនៅក្នុងក្រុង។

- **នីតិកាលទី៦ ផ្តោតលើ៖**

  ទី១.ការបន្តជំរុញដំណើរការកែទម្រង់ដីធ្លី និងការបង្កើនល្បឿននៃការកសាងផែនការមេ និងប្លង់គោលនៃការរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ទាំងថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ

  ទី២.ពង្រឹងសមត្ថភាពអនុវត្តការងារនគរូបនីយកម្ម,ការងារប្លង់គោលប្រើប្រាស់ដីរាជធានី,ការកសាងប្លង់គោលប្រើប្រាស់ដីក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់,ការរៀបចំយុទ្ធសាស្ត្រតម្រង់ទិសក្នុងការកំណត់បែងចែកតំបន់ប្រើប្រាស់ និងការគ្រប់គ្រងលំនៅឋាន ដោយប្រើប្រាស់បច្ចេកវិទ្យាព័ត៌មាន

  ទី៣.ការរៀបចំផែនការមេអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធទីក្រុង និងទីប្រជុំជន

  ទី៤.ការជំរុញការអភិវឌ្ឍន៍វិស័យសំណង់ និងការរៀបចំទីក្រុង ទីប្រជុំជន ពិសេសក្រុងប៉ោយប៉ែត និងក្រុងបាវិត

  ទី៥.ការបន្តពង្រឹងសោភ័ណភាព និងសោវាទីក្រុង ទីប្រជុំជន និងការអភិរក្សសំណង់ដែលមានតម្លៃប្រវត្តិសាស្ត្រ។



Domnakseuksa

# មុំទី៤.ការធានាចីរភាពបរិស្ថាន និងការរៀបចំខ្លួនឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុ

- **នីតិកាលកន្លងទៅសម្រេចបាន៖**ការពង្រឹងសមត្ថភាពបច្ចេកទេស និងស្ថាប័នក្នុងការគ្រប់គ្រងបរិស្ថាន,ការបញ្ជ្រាបការប្រែប្រួលអាកាសធាតុក្នុងគោលនយោបាយ បទដ្ឋានគតិយុត្ត និងផែនការ ទាំងថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ,គ្រប់គ្រងការបំពុលបរិស្ថាន ធនធានទឹក និងប្រព័ន្ធអេកូឡូស៊ី,បង្កើនសមត្ថភាពប្រើប្រាស់បច្ចេកវិទ្យា,ការចូលរួមចំណែកក្នុងការផលិតថាមពលស្អាត និងកិច្ចសហការជាមួយដៃគូអភិវឌ្ឍ ក្នុងការឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុ។
- **បញ្ហាប្រឈម៖**ការកើនឡើងនៃការប្រើប្រាស់ធនធានធម្មជាតិ,ការថយចុះគុណភាពបរិស្ថាន ទាំងទឹក ដី និងខ្យល់,សមត្ថភាពយល់ដឹងក្នុងការបញ្ជ្រាបបច្ចេកវិទ្យាដែលធន់ទៅនឹងការប្រែប្រួលអាកាសធាតុ ព្រមទាំងការសហប្រតិបត្តិការ និងការចូលរួមពីគ្រប់ភាគីពាក់ព័ន្ធនៅមានកម្រិត។

➢ **នីតិកាលទី៦ ផ្ដោតលើ៖**

**ទី១.**ការបន្តអនុវត្ត"ផែនការយុទ្ធសាស្ត្រជាតិស្ដីពីការអភិវឌ្ឍបៃតង ២០១៣-២០៣០","ផែនការយុទ្ធសាស្ត្រឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុកម្ពុជា ២០១៤-២០២៣", "យុទ្ធសាស្ត្រ និងផែនការសកម្មភាពបរិស្ថានជាតិ ២០១៦-២០២៣", "ផែនការយុទ្ធសាស្ត្រវេជបូកជាតិ", និងការប្រើប្រាស់មូលនិធិបរិស្ថានសង្គមឱ្យមានប្រសិទ្ធភាព

**ទី២.**ពង្រឹងការគ្រប់គ្រងតំបន់ការពារធម្មជាតិ អភិរក្សជីវៈចម្រុះ អភិរក្សសម្បត្តិធម្មជាតិ ពិសេសប្រព័ន្ធអេកូឡូស៊ីបឹងទន្លេសាប ទន្លេមេគង្គ និងតំបន់ឆ្នេរ

ទី៣.បន្តពង្រឹងការគ្រប់គ្រងសំណល់រឹង រាវ ឧស្ម័ន និងសារធាតុគ្រោះថ្នាក់
ទី៤.លើកកម្ពស់ការរស់នៅ ដោយមានប្រសិទ្ធភាព និងចីរភាពធនធាន
ទី៥.បង្កើនការប្រើប្រាស់បច្ចេកវិទ្យាភាតរបរិស្ថាន និងភាតរអាកាសធាតុ (ENVIRONMENTALLY-FRIENDLY AND CLIMATE-FRIENDLY TECHNOLOGIES)ក្នុងការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធ និងអភិវឌ្ឍន៍សង្គម-សេដ្ឋកិច្ច
ទី៦.បន្តជំរុញអនុវត្តយន្តការពាណិជ្ជកម្មកាបូន និងក្របខណ្ឌគតិយុត្តពាក់ព័ន្ធ,ការពង្រឹងសមត្ថភាពរៀបចំនិងអនុវត្តវិធានការ ដើម្បីបន្សាំ និងធន់ទៅនឹងការប្រែប្រួលអាកាសធាតុ និងសិក្សាពីភាពធន់ផ្នែកហិរញ្ញវត្ថុ
ទី៧.បន្តជំរុញការអភិវឌ្ឍ និងអនុវត្តផែនការគ្រប់គ្រងទឹកចម្រុះ
ទី៨.បន្តការលើកទឹកចិត្ត និងបង្កើនការវិនិយោគលើថាមពលស្អាត និងថាមពលកកើតឡើងវិញ
ទី៩.បន្តពង្រឹងក្របខណ្ឌគតិយុត្ត,អភិវឌ្ឍសមត្ថភាពជំនាញបរិស្ថាន ការអភិវឌ្ឍបៃតង ប្រែប្រួលអាកាសធាតុ ការគ្រប់គ្រងធនធានទឹកចម្រុះ និងការប្រើប្រាស់ធនធានធម្មជាតិប្រកបដោយចីរភាព។